**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សារជូនពរ**

**សូមគោរពជូន**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា**
**នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាធម្មពោធិសាល ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ **មមែ** សប្តស័ក ព.ស ២៥៥៩ គ.ស ២០១៥ នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមចូលរួមអបអរសាទរចំពោះលទ្ធផលដ៏ត្រចះត្រចង់ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ កន្លងមក ដែលបានជ្រើសតាំង **សម្តេចអគ្គមហាធម្មពោធិសាល** បានជាប់ឆ្នោតជាថ្មីម្តងទៀត ជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះមេត្តាប្រោសប្រទាន ប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរជូន **សម្តេចប្រធាន** ជាទីគោរពដ៏ខ្ពង់ខ្ពស់ ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ និងទទួលបានជោគជ័យថ្មីៗ ថែមទៀត ក្នុងបេសកកម្មដឹកនាំព្រឹទ្ធសភា រួមចំណែកពង្រឹងនីតិរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយសុខសន្តិភាព និងអភិវឌ្ឍន៍មាតុភូមិកម្ពុជាឲ្យបានថ្កុំថ្កើងសម្បូររុងរឿង សមតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋទូទាំងប្រទេសជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចអគ្គមហាធម្មពោធិសាល** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**